# គំនិតសម្រាប់គម្រោងដែលនៅសេសសល់

ដោយ ស៊ឹម សូរិយា ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១

គោរពជូនលោកចៅក្រម យូ ឧត្តរា លោកស្រីចៅក្រម FENZ និងលោក កែវ សុទ្ធី!

ជាការឆ្លើយតបចំពោះការស្នើសុំឲ្យមានការចូលរួមជាគំនិត ខ្ញុំមានកិត្តិយសសូមលើកឡើងនូវគំនិតដូចខាងក្រោម។ គំនិតរបស់ខ្ញុំបែងចែកជាពីរផ្នែក។ ផ្នែកទីមួយរៀបចំជាទស្សនៈខ្លី។ ផ្នែកទីពីរ រៀបរាប់នូវគំនិត ដែលអាចមិនមានទំនាក់ទំនងគ្នាជិតដិត។

ដោយសេចក្តីគោរព

ស៊ឹម សូរិយា

I. **ការរួចផុតពីក្តីអាម៉ាស់**

កិច្ចពិភាក្សារបស់អតីតជនរងគ្រោះរបបខ្មែរក្រហម តាមរយៈការដោះស្រាយទំនាស់ ក្រៅប្រព័ន្ធតុលាការ (ADR)

អ.វ.ត.ក បានបង្ហាញថា គណនេយ្យភាព និងការផ្សះផ្សារ គឺមិនមែនជារឿងពីរដាច់ដោយឡែកពីគ្នានោះទេ។ អ.វ.ត.ក មិនគ្រាន់តែស្វែងរកយុត្តិធម៌ប៉ុណ្ណោះទេ អ.វ.ត.ក ថែមទាំងកំណាត់អត្តសញ្ញាណចារីនៅក្នុងតុលាការ ដោយជម្រះបុគ្គលជាច្រើនចេញពីសេចក្តីអាម៉ាស នៅក្នុងសហគមន៍។

**គោលបំណង**៖ គម្រោងនេះមានគោលដៅ ដើម្បីស្វែងរកសមាជិកក្នុងសហគមន៍ ដែលយល់ថាបានជាសះស្បើយ ឬបានផ្សះផ្សារតាមរយៈការចូលរួមជាមួយ អ.វ.ត.ក ឬតាមរយៈការដឹងអំពី អ.វ.ត.ក និងដើម្បីធានាថាសហគមន៍ស្ថិតក្នុងសន្តិភាព និងការអភិវឌ្ឍន៍។ គោលបំណងទាំងនោះរួមមាន៖

១. ការថែរក្សាការផ្សះផ្សារ តាមរយៈការពិភាក្សាតាមបែបការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ (ADR) និងការព្យាបាលនូវក្តីអាម៉ាស់

២. ផ្តល់ដល់សហគមន៍ នូវជំនាញនៃការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ (ADR) ដែលនឹងព្យាបាលបញ្ហាអតីតកាល និងពង្រឹងសុខុមាលភាពនាពេលបច្ចុប្បន្ន

៣. ទទួលបានលទ្ធផលប្រកបដោយអត្ថន័យ ជារូបីយ៍ និងមានចិរភាព នៅកម្រិតមូលដ្ឋាន ដោយឲ្យជនរងគ្រោះធ្វើជាតំណាងឲ្យខ្លួនឯង និងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមសោតទស្សន៍ ដើម្បីចូលរួមជាមួយសហគមន៍។

**សកម្មភាព៖** ការពិនិត្យមើលលើគម្រោងនិងសម្ភារៈរបស់ អ.វ.ត.ក/អង្គភាពគាំពារជនរងគ្រោះ/ផ្នែកកិច្ចការសាធារណៈ និង CSOs បានបង្ហាញអំពីរឿងរ៉ាវនៃការព្យាបាល ដូចជាការមកធ្វើទស្សនកិច្ចនៅតុលាការ ការផ្សព្វផ្សាយរបស់ផ្នែកកិច្ចការសាធារណៈ វេទិការបស់អង្គភាពគាំពារជនរងគ្រោះ និងការងារដទៃទៀត។ គម្រោងល្អបំផុត ដែលបំពេញបានតាមគោលបំណងទាំងអស់ខាងលើ គឺជា "គម្រោងរួចផុតពីក្តីអាម៉ាស់" បច្ចុប្បន្ន ដែលរៀបចំឡើងដោយអង្គការក្តីករុណា និងអង្គការចិត្តសង្គម អន្តរវប្បធម៌។ គម្រោងនេះរួមមានដំណាក់កាលដូចតទៅ៖ ១) ការកំណត់អត្តសញ្ញាណ និងការវាយតម្លៃលើអ្នកចូលរួមក្នុងគម្រោង ២) ការពិភាក្សាតាមរយៈវីដេអូ ៣) ការពិភាក្សាទល់មុខគ្នា ៤) លទ្ធផលជាក់ស្តែង។ ដំណាក់កាលទី១ដល់ទី៣ ធ្វើឡើងតាមវិធីសាស្ត្រចរចារ ដែលរួមមានការយល់ព្រម ការស្វែងរកការពិត និងគោលជំហរ (ការភ័យខ្លាច/ការរើសអើង) ការស្វែងរកជម្រើសនិងផលប្រយោជន៍រួម។ អ្នកសម្របសម្រួលកិច្ចពិភាក្សា ត្រូវបានបណ្តុះបណ្តាល ឬត្រូវទទួលការបណ្តុះបណ្តាល ដើម្បីពួកគាត់អាចបណ្តុះបណ្តាល សមាជិកនៅក្នុងសហគមន៍ នៅក្នុងលទ្ធផលដំណាក់កាលទីបួន នាពេលបន្ទាប់។ លទ្ធផលទទួលបានរួមមាន ក) ការបណ្តុះបណ្តាលដល់សមាជិកសហគមន៍នូវជំនាញការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ (ADR) នឹងជួយឲ្យមានការទំនាក់ទំនង ប្រកបដោយប្រសិទ្ធិភាព ដោយលប់បំបាត់ក្តីអាម៉ាស់ពីអតីតកាល និងការរើសអើងនាពេលបច្ចុប្បន្ន ឬទៅអនាគត។ ខ) រួមបញ្ចូលនូវខ្សែភាពយន្តនិងការផ្សព្វផ្សាយ គ) មានការរៀបចំវីដេអូខ្លីៗអំពីដំណើរការ និងលទ្ធផល ហើយត្រូវបានផ្សព្វផ្សាយលើប្រព័ន្ធបណ្តាញសង្គម ដើម្បីអាចផ្សព្វផ្សាយទៅទស្សនិកជនបានច្រើនជាអតិបរមា ឃ) សៀវភៅរៀបរាប់ពីការព្យាបាលអតីតកាល និងការប្រើប្រាស់ជំនាញ ការដោះស្រាយទំនាស់ ក្រៅប្រព័ន្ធតុលាការ (ADR) ដើម្បីដោះស្រាយទំនាស់បច្ចុប្បន្ន គឺជាសកម្មភាពធានានូវចិរភាពនៃគម្រោង ង) គេហទំព័រ

ស្ទង់មតិ Google ដែលសហគមន៍គោលដៅ អាចបង្ហាញគំនិតយោបល់ គឺជាមធ្យោបាយនៃការវាយតម្លៃសម្រាប់កែលម្អគម្រោងដែលកំពុងដំណើរការ។

*សកម្មភាពដែលមានស្រាប់*

គម្រោងកិច្ចពិភាក្សារបស់អតីតជនរងគ្រោះរបបខ្មែរក្រហម (GIZ/អង្គការក្ដីករុណា /អង្គការចិត្តសង្គម អន្តរវប្បធម៌ ឆ្នាំ ២០១១) បានកំណត់អត្តសញ្ញាណជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម ដែលរស់នៅក្នុងសហគមន៍។ ពួកគេធ្វើការវាយតម្លៃទៅលើតម្រូវការនៃការពិភាក្សា ដោយអនុញ្ញាតឲ្យប្រជាជន រៀបរាប់ពីហេតុការណ៍នាអតីតកាល បង្ហាញពីការយល់ព្រមក្នុងការចូលរួមក្នុងគម្រោង និងអារម្មណ៍និងទស្សនៈបច្ចុប្បន្នរបស់ពួកគេ អំពីហេតុការណ៍ទាំងអស់នោះ និងអំពីសមមិត្តទាំងអស់នោះ។ ដោយមានការអនុញ្ញាត អំពីកម្រិតនៃការបង្ហាញអត្តសញ្ញាណ ពួកគេថតជាវីដេអូនូវព័ត៌មានទាំងនោះ ហើយបង្ហាញទៅដល់ជនរងគ្រោះពាក់ព័ន្ធនៃរបបខ្មែរក្រហម។ អង្គការក្ដីករុណាធ្វើការសម្របសម្រួលលើកិច្ចពិភាក្សា ឯអង្គការចិត្តសង្គម អន្តរវប្បធម៌ទទួលខុសត្រូវលើការគាំទ្រផ្នែកចិត្តសាស្ត្រ និងការអន្តរាគមន៍។ លទ្ធផលសម្រេចមួយ ក្នុងចំណោមលទ្ធផលនានា គឺសហគមន៍បានសហការរួមគ្នា កសាងចេតិយមួយឡើង។ ជារួម ការវាយតម្លៃបង្ហាញថា សហគមន៍អាចទំនាក់ទំនងគ្នា បានល្អប្រសើរជាងមុន។ នេះគឺជាមធ្យោបាយមួយ យ៉ាងហោចណាស់អាចកាត់បន្ថយការរើសអើង ឬក្ដីអាម៉ាស់ ប្រសិនបើមិនអាចលប់បំបាត់ទាំងស្រុង[i]។

*វិធីសាស្ត្រការដោះស្រាយទំនាស់ ក្រៅប្រព័ន្ធតុលាការ (ADR) រួមបញ្ចូលជាមួយការពិភាក្សា និងការព្យាបាលដែលមានស្រាប់*

វិធីសាស្ត្រដោះស្រាយទំនាស់ ក្រៅប្រព័ន្ធតុលាការ (ADR) ប្រើប្រាស់ភាសានិងជំនាញដោះស្រាយទំនាស់បែបអព្យាក្រិត។ វិធីនេះស្វែងរកការពិតទាំងអស់នៃហេតុការណ៍មួយ នៅក្នុងវគ្គចង្អៀត/ទូលាយ បន្ទាប់មកអនុញ្ញាតឲ្យភាគី ទំនាក់ទំនងគ្នាដោយផ្ទាល់ ដែលការនេះនឹងលប់បំបាត់ការភ័យខ្លាច (ការខូចខាត/ការរើសអើង) ដើម្បីស្វែងរក និងទទួលយកនូវផលប្រយោជន៍រួមគ្នា។ ជំនាញទាំងនេះអាចបង្ហាញ និងបង្រៀនដល់ជនរងគ្រោះ ក៏ដូចជាសមមិត្តនានា។ ពួកគាត់មិនត្រឹមតែអាចដោះស្រាយ ការយល់ច្រឡំពីអតីតកាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចប្រើប្រាស់ជំនាញនេះ សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ គឺជំនាញដោះស្រាយទំនាស់ក្នុងការរកស៊ី

និងការទំនាក់ទំនងដទៃទៀត។ ក្នុងលក្ខណៈនេះ ការបណ្តុះបណ្តាលគ្រូបង្គោល អាចបង្កើតឲ្យមាននូវចេរភាពនៃគម្រោង។

**ភាពជោគជ័យ និងបញ្ហាប្រឈម**៖ ភាពជោគជ័យអាស្រ័យលើថាតើ ក្រុមការងារគម្រោង អាចរកឃើញរឿងរ៉ាវនៃក្តីអាម៉ាស់ដែរឬទេ។ ការសន្មតទុកគឺថា អង្គការក្តីករុណា/អង្គការចិត្តសង្គម អន្តរវប្បធម៌ អាចរកឃើញ។ បើមិនអាចរកឃើញទេ ផែនការបន្ទាប់គឺក្រុមការងារ អ.វ.ត.ក ធ្វើការពិនិត្យមើលលើបញ្ជី អតីតសាក្សីរបបខ្មែរក្រហម ហើយធ្វើការសាកសួរពួកគាត់។ ការនេះអាចសម្រេចទៅបាន។

## II. កេរ្តិ៍តំណែលផ្លូវច្បាប់ និងការសិក្សាស្រាវជ្រាវ

១. អ.វ.ត.ក ប្រមូលផ្តុំបញ្ហាអង្គហេតុ និងអង្គច្បាប់សំខាន់ៗ។ ប្រើប្រាស់បណ្ណាសាររបស់ អ.វ.ត.ក ប្រើប្រាស់សិស្សនិសិត្សធ្វើការស្រាវជ្រាវ និងបង្កើតឯកសារបោះពុម្ពផ្សាយ។

២. គម្រោងតុលាការត្រាប់ ស្តីពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ដោយសហការណ៍ជាមួយកម្មវិធីតុលាការត្រាប់ របស់សាកលវិទ្យាល័យនៅកម្ពុជា ដោយផ្តល់នូវការប្រមូលផ្តុំ និងសិទ្ធិចូលពិនិត្យមើលធនធាននានា ដោយមានការចូលរួមពីអតីតមន្ត្រីរបស់ អ.វ.ត.ក និងអ្នកវិជ្ជាជីវៈដទៃទៀត ដើម្បីបង្ហាត់បង្ហាញ ឬចែករំលែកបទពិសោធន៍។ ធ្វើការភ្ជាប់ទំនាក់ទំនង តុលាការត្រាប់នេះជាមួយកម្មវិធីរបស់សាកលវិទ្យាល័យអន្តរជាតិដទៃទៀត។

៣. ថ្នាក់រៀនច្បាប់ព្រហ្មទណ្ឌកម្ពុជា។ ច្បាប់សារធាតុ និងច្បាប់នីតិវិធីកម្ពុជា មានយុត្តិសាស្ត្រនៅក្នុង អ.វ.ត.ក។ រៀបចំចំណុចទាំងនេះជាផ្នែកមួយនៃការចងក្រង (១)។

៤. ការកែលម្អលើផ្នែកបច្ចេកវិទ្យា និងបច្ចេកទេស នៃតុលាការកម្ពុជា ដោយប្រើប្រាស់បទពិសោធន៍របស់ អ.វ.ត.ក ឬធនធានប្រហែលនេះ។ ការនេះអាចធ្វើទៅបានតាមរយៈ ទីមួយបង្កើតគណៈកម្មការធ្វើការសិក្សាពីលទ្ធភាព និងរៀបចំផែនការ។ គួរចាប់ផ្តើមដំបូងជាមួយតុលាការតែមួយ ដែលប្រព័ន្ធតុលាការថ្មី (ដូចជាការគ្រប់គ្រងសំណុំរឿង ការដេញដោលក្នុងសាលសវនាការ) ធ្វើឡើងតាមរចនាសម្ព័ន្ធរូបវន្ត ឬឌីជីថលផ្សេងពីគ្នា ដោយចុះបញ្ជីសំណុំរឿងថ្មី ចាប់តាំងពីពេលចាប់ផ្តើម រហូតដល់បញ្ចប់កិច្ចដំណើរការនីតិវិធី ហើយបញ្ចូលក្នុងបណ្ណាសារ ដោយមិនធ្វើឲ្យប៉ះពាល់ដល់លេខសំណុំរឿង

និងនីតិវិធីផ្លូវច្បាប់ដែលមានស្រាប់។ នៅពេលដែលប្រព័ន្ធថ្មីមួយដំណើរការ អាចធ្វើការពិចារណាបន្ត ថាតើ ត្រូវបញ្ចូលសំណុំរឿងចាស់ៗ ទៅក្នុងប្រព័ន្ធនោះដែរឬអត់ ហើយបើបញ្ចូល តើបញ្ចូលត្រឹមកម្រិតណា។ អតីតមន្ត្រី អ.វ.ត.ក និងអ្នកជំនាញវិជ្ជាជីវៈដទៃទៀត អាចជួយបានក្នុងបញ្ហានេះ។

៥. ក្រុមវិជ្ជាជីវៈ និងការទូត ដែលមានភារកិច្ចបើកយុទ្ធនាការ និងលើកកម្ពស់ទាំងនៅកម្រិតជាតិ និងកម្រិតអន្តរជាតិ អំពីការប្រើប្រាស់ អ.វ.ត.ក ធ្វើជាគម្រូសម្រាប់តុលាការមានលក្ខណៈអន្តរជាតិដទៃផ្សេងទៀត។

**កំណត់ត្រាចុងក្រោយ** (ENDNOTE)

---

[i] https://www.kdei-karuna.org/publication
https://www.youtube.com/watch?v=_F-yVZup2xI&t=4s
Rothany SRUN, TIM Minea, Judith STRASSER, Dr. MUNY Sothara, CHHAY Marideth, YOURN Sarath គម្រោងពិភាក្សាជនរងគ្រោះនៃអតីតរបបខ្មែរក្រហម៖ មេរៀនដែលទទួលបាន។ រាជធានីភ្នំពេញ៖ មជ្ឈមណ្ឌលអន្តរជាតិ សម្រាប់ការផ្សះផ្សារ (អង្គការក្ដីករុណា) និង អង្គការចិត្តសង្គម អន្តរវប្បធម៌ ខែធ្នូ ឆ្នាំ ២០១១ (ចំនួន ៤៧ទំព័រ ឧបត្ថម្ភដោយអង្គការ GIZ) (របាយការណ៍ស្ដីពីការពិភាក្សា)។